98-ECOO13

# PRESS RELEASE

# សេចក្តីប្រកាសព័ត៌មាន

December 28th, 1998

## NOTE TO EDITORS-PHOTO OPPORTUNITY

### The Inauguration Ceremony of the Two School Buildings in the Chamkar Sbouv Primary School

**December 31st, 1998**
**at 9:00 a.m. at the Chamkar Sbouv Primary School in Toul Sambo Commune, Oring Orv District, Kompong Cham Province**

This ceremony is to inaugurate the two new school buildings at the Chamkar Sbouv Primary School in the presence of H.E. Mr. Sar Kheng, Deputy Prime Minister and Co-Minister for Interior, H.E. Mr. Hun Neng, Governor of Kompong Cham Province and H.E. Mr. Masaki Saito, Ambassador of Japan.

The construction of these buildings of 5-classroom each with education equipment was conducted by The Outreach, a Cambodian NGO working in human right and community development fields, for the benefit of approximately 1,200 pupils and teachers. The Government of Japan funded The Outreach with US$ 49,220, on the grant contract singed on November 12th, 1997, through the Japanese Grant Assistance for Grass-Roots Projects Scheme called "KUSANONE".

The KUSANONE is the Japan's grant aid to support small-scale, grass-roots projects by NGOs or local authorities and is an important pillar of Japan's economic cooperation to Cambodia. Since its start in 1992, the total amount of US$ 5,885,139 KUSANONE grant has been provided to assist 117 projects in Cambodia to help Cambodian rehabilitation and development efforts at the grass-roots level.

* * *

Editors are invited for reporting and photo coverage.

---

**Embassy of Japan No. 75, Preah Norodom Blvd. Tel: (023) 217 161/4 Fax: 855 023 216 162**

98-ECOO13

# PRESS RELEASE　　សេចក្តីប្រកាសពត៌មាន

ថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៨

## ពិធីសម្ពោធអាគារសិក្សា២ខ្នង នៅសាលាបឋមសិក្សាចំការស្បូវ
## នៅថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៨
## នៅវេលាម៉ោង ៩:00 ព្រឹក នៅសាលាបឋមសិក្សាចំការស្បូវ
## នៅឃុំទួលសំបូរ ស្រុកអូររាំងឪ ខេត្តកំពង់ចាម

ពីធីសម្ពោធអាគារសិក្សាថ្មី២ខ្នងនៅសាលាបឋមសិក្សាចំការស្បូវ នឹងប្រព្រឹត្តទៅក្រោមអធិបតីភាពរបស់ឯកឧត្តម ស ខេង ឧបនាយករដ្ឋមន្ត្រី និង រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ឯកឧត្តម ហ៊ុន ណេង អធិបាលខេត្តកំពង់ចាម និង ឯកឧត្តម ម៉ាសាគី សៃតូ ឯកអគ្គរដ្ឋទូតជប៉ុន ។

អាគារសិក្សាទាំងនេះ ដែលមួយខ្នងៗមាន៥បន្ទប់ ប្រកបដោយសំភារៈអប់រំ ត្រូវបានកសាងដោយអង្គការ The Outreach ដែលជាអង្គការក្រៅរដ្ឋាភិបាលកម្ពុជាមួយកំពុងបំរើការងារនៅក្នុងផ្នែកសិទ្ធិមនុស្ស និង ការអភិវឌ្ឍន៍សហគមន៍ សំរាប់ជាប្រយោជន៍ដល់លោកគ្រូអ្នកគ្រូ និង សិស្សានុសិស្សប្រមាណ ១.២០០ នាក់ ។ ដោយផ្អែកតាមកិច្ចព្រមព្រៀងផ្តល់ជំនួយដែលបានចុះហត្ថលេខា នៅថ្ងៃទី ១២ ខែ វិច្ឆិកា ឆ្នាំ ១៩៩៧ រដ្ឋាភិបាលជប៉ុនបានផ្តល់ថវិការដល់អង្គការ The Outreach នូវទឹកប្រាក់ចំនួន ៤៩.២២០ ដុល្លាអាមេរិក តាមរយៈជំនួយឧបត្ថម្ភរបស់ជប៉ុនដល់គំរោងការទ្រង់ទ្រាយតូច ហៅថា “គូសាណូណេ”។

“គូសាណូណេ” គឺជាជំនួយឧបត្ថម្ភរបស់ជប៉ុនមួយបែប ដើម្បីជួយដល់គំរោងការតូចៗនៅតាមមូលដ្ឋាន ដែលផ្តួចផ្តើមគំនិតឡើងដោយអង្គការក្រៅរដ្ឋាភិបាល ឬ ដោយអាជ្ញាធរមូលដ្ឋាន ហើយក៏ជាសសរទ្រូងមួយដ៏សំខាន់នៃជំនួយសហប្រតិបត្តិការសេដ្ឋកិច្ចរបស់ជប៉ុននៅកម្ពុជាផងដែរ ។ ចាប់តាំងពីការផ្តើមអនុវត្តជំនួយឧបត្ថម្ភបែបនេះនៅឆ្នាំ ១៩៩២ មក “គូសាណូណេ” បានផ្តល់ទឹកប្រាក់សរុបចំនួន ៥.៨៨៥.១៣៩ ដុល្លាអាមេរិកហើយ សំរាប់ ១១៧ គំរោងការនៅកម្ពុជា ដើម្បីជួយដល់ការខិតខំប្រឹងប្រែងស្តារ និង អភិវឌ្ឍន៍ឡើងវិញតំបន់ជនបទនៃកម្ពុជា ។

♣♣♣

អ្នកយកពត៌មានទាំងអស់ត្រូវបានអញ្ជើញអោយចូលរួមដើម្បីយកពត៌មាន និង ថតរូបភាព

ស្ថានទូតជប៉ុន លេខ ៧៥ មហាវិថីព្រះនរោត្តម ទូរស័ព្ទលេខ: ០២៣ ២១៧ ១៦១/៤ ហ្វាក់លេខ: ០២៣ ២១៦ ១៦២